ក្រសួងយុត្តិធម សហរដ្ឋអាមេរិក

ការិយាល័យសិទ្ធិពលរដ្ឋ

# កិច្ចការពាររបស់សហព័ន្ធប្រឆាំងនឹងការប្រកាន់រើសអើងសញ្ជាតិដើម



# សេចក្ដីផ្ដើម

ច្បាប់សហព័ន្ធហាមមិនឱ្យប្រកាន់រើសអើងចំពោះជនណាម ាក់ ដោយយោងទៅលើសញ្ជាតិដើម ពូជសាសន៍ ពណ៌ សម្បុ រ សាសនា ពិការភាព ភេទ និងវណ្ណ ៈគ្រួសាររបស់គេឡើយ ។ ច្បាប់ដែលហាមឃាត់មិនឱ្យប្រកាន់រើសអើងចំពោះសញ្ជាតិដើម ចាត់ទុកការប្រកាន់រើសអើងដែលយោងទៅលើ ទីកន្លែងកំណើត ពូជពង្ស វប្បធម៌ ឬភាសា ថាល្មើសនឹងច្បាប់ ។ នេះមានន័យថា គេមិនអាចរារាំងមិនឱ្យជនណាម្ន ាក់មាន ឱ កាសស្មើគ្ន ា ដូចមនុស្សឯ ទៀត ក្ន ុ ងការធ្វើអ្វីមួយ ដោយសារខ្លួ នគេ ឬគ្រួសាររបស់គេមកពីប្រទេសមួយទៀត ដោយមកពីគេមានឈ្មោះ ឬមានរបៀបនិយាយ ទាក់ទងនឹង ក្រុមជាតិសាសន៍ ណាមួយ ឬដោយសារសមត្ថភាពភាសាអង់គ្លេសរបស់គេមានកម្រិត ឬដោយមកពីគេចូលរួមក្ន ុ ងពិធីប្រពៃ ណីខ្លះៗ ទាក់ទងនឹងក្រុមជាតិសាសន៍អ្វីមួយ ឬ ដោយមកពីគេរៀបការជាមួយ ឬទាក់ទងនឹងមនុស្សមានសញ្ជាតិដើមអ្វីមួយឡើយ ។

ការិយាល័យសិទ្ធិមនុស្សនៃ នក្រសួងយុត្តិធម៌ ព្រួយបារម្ភ ថា អាចគ្មានអ្ន ករាយការណ៍អំពីការប្រកាន់រើសអើងចំពោះសញ្ជាតិដើម នៅ ស.រ.អា ដោយ មកពីជនរងគ្រោះដោយការប្រកាន់រើសអើងមិនដឹងពីសិទ្ធិស្របច្បាប់របស់ខ្លួ ន ឬអាចក្លាចមិនហ៊ ានតវ៉ានឹងរដ្ឋាភិបាល ។ បើអ្ន កយល់ថា ខ្លួ នអ្ន ក ឬអ្ន កណាម្ន ាក់ដែលអ្ន កស្គាល់ ត្រូវគេប្រកាន់រើសអើងប្រឆាំងនឹងសញ្ជាតិដើម ហើយចង់ស្វែងយល់ បន្ថែមទៀតអំពីសិទ្ធិស្របច្បាប់របស់អ្ន ក អ្ន កគួរអានកូន សៀវភៅ ផ្សព្វផ្សាយនេះ ។

កូនសៀវភៅផ្សព្វផ្សាយនេះ ពន្យ ល់អំពីច្បាប់ដែលហាមមិនឱ្យប្រកាន់រើសអើងសញ្ជាតិដើមរបស់ជនណាម្ន ា

ក់ ហើយមាន ផ្តល់នូវឧទាហរណ៍ខ្លះៗ ផងដែរ ។

អ្ន កក៏អាចស្វែងរកព័តិ មានបន្ថែមអំពីការិយាល័យសិទ្ធិពលរដ្ឋ និងផ្នែ កតូចៗ នៃការិយាល័យនេះ ។ តាមរយៈអាសយដ្ឋានអ៊ីនធឺណិត http://www.justice.gov/crt ។ អ្ន កអាចទាក់ទងការិយាល័យនេះ ដើម្បីរាយការណ៍អំពីការតវ៉ារឿងប្រកាន់រើសអើងដូចមានពន្យ ល់ខាងក្រោមនេះ ប្រសាប់ ។

## ការដឹងយល់អំពីសិទ្ធិស្របច្បាប់របស់អ្ន ក

ការិយាល័យសិទ្ធិពលរដ្ឋនៃ នក្រសួងយុត្តិធមិ អនុវត្តច្បាប់សហព័ន្ធ ដែលហាមឃាត់មិនឱ្យមានការប្រកាន់រើសអើងក្នុ ងវិស័យដូចតទៅ:

ការសិក្សាអប់រំ
ការងារ
ការផ្តល់ជម្រក
ការឱ្យខ្ចីប្រាក់
ការប្រើសេវាសាធារណៈ
ការអនុវត្តន៏ច្បាប់/ការប្រព្រឹត្តខុសក្រមសីលធមិ របស់នគរបាល
ការបោះឆ្នោ ត
កម្មវិធីទទួលជំនួយពីសហព័ន្ធ

ការិយាល័យនេះក៏អនុវត្តផងដែរ នូវច្បាប់ដែលហាមមិនឱ្យមានការរើសអើងចំពោះពិការភាព ការពារ សិទ្ធិពលរដ្ឋរបស់អ្ន កដែលត្រូវបានដាក់ឱ្យ នៅក្នុ ងគ្រឹះស្ថានរដ្ឋ ឬក្នុ ងមូលដ្ឋាន ហើយកាត់ទោសនូវបទឧក្រិដ្ឋ ដែលកើតឡើងដោយសារតែពូជសាសន៏ ពណ៌ សម្បុ រ ឬសញ្ជាតិកំណើត របស់ជនរងគ្រោះ ។

នៅក្នុ ងករណីមួយចំនួន ការិយាល័យនេះអាចនឹងជំពាក់ទាក់ទិនក្នុ ងរឿងនោះ តែនៅក្នុ ងករណីណា ដែលមាន "គំរូ ឬការអនុវត្តន៏" ការរើសអើង ។ "គំរូ

ឬការអនុវត្តន៍" ជាទូទៅ មានន័យថា មានការរើសអើងច្រើនជាង ម្តង ហើយមានគោលនយោបាយ ឬការ ប្រព្រឹត្តនូវអំពើរើសអើង ម្តងហើយម្តងទៀត។

## ការប្រព្រឹត្តបទឧក្រិដ្ឋទៅលើសិទ្ធិពលរដ្ឋ

**យុវជនម្ន ាក់មានដើមកំណើតជាជនជាតិអាស៊ីខាងត្បូ ង ត្រូវមនុស្សវាយដំពេលគាត់ចេញពីមើលការប្រគុំតន្ត្រីនៅឯ ក្លឹបរាត្រីមួយ។ អ្ន កវាយដំគាត់ ដែលជាសមាជិកក្រុមស្គិនហ៊ែ ត (Skinhead) ស្រែកឱ្យយុវជននេះ ដោយប្រើពាក្យ មើលងាយប្រមាថពូជសាសន៍ នៅពេលដែលគេដាល់ និងប្រើបំពង់ដែក វាយជនរងគ្រោះនោះរហូតទាល់តែសន្លប់នៅនឹងកន្លែងចតរថយន្តនៃ ទក្លឹបរាត្រីនោះ។*

**នៅពេលប្រជុំក្រុមគូគ្លុ កក្លាន់ (Ku Klux Klan) សមាជិកក្រុមនេះប្រាប់ទៅសមាជិកដទៃ ទទៀតថា ជនជាតិម៉ិចស៊ិកូ និងជនជាតិព័រតូរីកូគួរ "ត្រឡប់ទៅ ប្រទេសរបស់ខ្លួ នវិញ"។ ពួកគេដុតឈើឆ្កា ងក្ន ុ ងទីលានមុខផ្ទះរបស់ប្តីប្រពន្ធជាតិអេស្ប៉ាញមួយគូ ដើម្បីបន្លាចពួកគេ ហើយបង្ខ ំឱ្យពួកគេផ្លាស់ផ្ទះចេញពីសង្កា ត់ នោះទៅ។ មុននឹងដុតឈើឆ្កា ង ចុងចោទ បានបង្ហាញកាំភ្លើង ហើយឱ្យកាំភ្លើងមួយទៀតទៅមិត្ត របស់គេម្នា ក់ ក្ន ុ ងករណីជនរងគ្រោះព្យា យាមបញ្ឈ ប់ពួកគេ។*

**ក្រុមហ៊ុ នអាមេរិកកាំងមួយជ្រើសរើសកម្មករនៅក្ន ុ ងទីក្រុងតូចមួយនៅប្រទេសម៉ិចស៊ិចកូ ដោយសន្យា នឹងពួកគេថា នឹងផ្តល់ការងារល្អ និងប្រាក់បៀវត្សន៍ ខ្ពស់។ ក្រុមហ៊ុ ននោះបានលួចនាំជនជាតិម៉ិចស៊ិចកូនោះដោយខុសច្បាប់ចូល ស.រ.អា ដោយលាក់ក្ន ុ ងរថយន្តដឹកវត្ថុ រាវ (tanker truck) ទទេមួយ។ នៅពេលពួកគេមកដល់សហរដ្ឋអាមេរិក កម្មករទាំងនោះត្រូវគេគំរាមគំហែងថា បើពួកគេរត់ចោលរោងចក្ររបស់គេ នោះ ពួកគេនឹងត្រូវសម្លាប់ចោល។*

ឧទាហរណ៍ទាំងនេះ អាចតំណាងឱ្យការប្រព្រឹត្តបទឧក្រិដ្ឋលើច្បាប់ស្ដីពីសិទ្ធិពលរដ្ឋ។ ផ្នែកឧក្រិដ្ឋកម្មនៃការិយាល័យសិទ្ធិពលរដ្ឋកាត់ទោសជនដែលត្រូវគេចោទថាបានប្រើកម្លាំង ឬអំពើរហិង្សា ដែលប៉ះពាល់ដល់សិទ្ធិរបស់ជនណាម្នាក់ដែលសហព័ន្ធការពារ ដោយសារតែសញ្ជាតិដើមរបស់គេ។ សិទ្ធិទាំងនោះ រួមមាន ការផ្ដល់ទីជម្រក ការងារ ការសិក្សាអប់រំ ឬការប្រើសេវាសាធារណៈ។ លោកអ្នកអាចទំនាក់ទំនងផ្នែកឧក្រិដ្ឋកម្មនេះតាមរយៈទូរស័ព្ទលេខ (202) 514-3204 ឬសរសេរសំបុត្រទៅកាន់អាសយដ្ឋាន:

U.S. Department of Justice
Civil Rights Division
Criminal Section, PHB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## សិទ្ធិរបស់ជនពិការ

** អង្គការថែរក្សាសុខភាព (HMO) មួយដែលទទួលចុះឈ្មោះអ្នកជំងឺមេឌិកអេដ (Medicaid) បានប្រាប់ទៅស្ត្រីអាមេរិកកាំង ដើមកំណើតម៉ិចស៊ិចកូម្នាក់ដែលមានជំងឺរីកលចលនាសរសៃខួរក្បាល ជាអចិន្ត្រៃយ៍ (cerebral palsy) ឱ្យត្រឡប់មកម្ដងទៀតនៅថ្ងៃក្រោយ ដើម្បីធ្វើការណាត់ជួប ខណៈពេលអង្គការនេះកំពុងតែផ្ដល់ជំនួយជាបន្ទាន់ ដល់អ្នកជំងឺដទៃទៀត។*

ឧទាហរណ៍នេះអាចចាត់ថាជាការរំលោភលើច្បាប់សហព័ន្ធ ដែលហាមឃាត់មិនឱ្យប្រកាន់រើសអើងដោយសារពិការភាព ក៏ដូចជាច្បាប់ដែលហាមឃាត់មិនឱ្យប្រកាន់រើសអើងចំពោះសញ្ជាតិដើម។ បើអ្នកជឿជាក់ថាអ្នកត្រូវបានគេប្រកាន់រើសអើង ដោយសារអ្នកមានពិការភាព អ្នកអាចទំនាក់ទំនង ផ្នែកសិទ្ធិជនពិការតាមរយៈលេខ (800) 514-0301 (សម្លេង) ឬ (800) 514-0383 (TTY) ឬផ្ញើអ៊ីមែលមកកាន់ ada.complaint@usdoj.gov។ អ្នកក៏អាចសរសេរសំបុត្រទៅអាសយដ្ឋាន:

U.S. Department of Justice
Civil Rights Division
Disability Rights Section, NYA
950 Pennsylvania Avenue, NW
Washington, D.C. 20530

## ការសិក្សាអប់រំ

*ក្មេងម្ន ាក់មានភាពលំបាកក្ន ុ ងការនិយាយភាសាអង់គ្លេស ប៉ុន្តែសាលារៀនដែលក្មេងនោះរៀន មិនផ្តល់ការណែនាំ និងសេវាសមស្រប ដើម្បីជួយឱ្យនាងរៀន ភាសាអង់គ្លេស និងមុខវិជ្ជាសិក្សាផ្សេងៗទៀតទេ។

*សាលារៀនមានកូនក្មេងជាជនជាតិ ៃ ហទីភាគច្រើនរៀន មិនបង្រៀនមុខវិជ្ជាសំរាប់សិស្សរៀនពូកែ (honors classes) ទេ។ សាលារៀនដ ៃ ទទៀត ដែលគ្មាន កូនសិស្សជាជនជាតិ ៃ ហទីច្រើនរៀនទេនោះ មានមុខវិជ្ជាសំរាប់សិស្សរៀនពូកែ និងមុខវិជ្ជាសំរាប់សិក្សាជាន់ខ្ពស់ (advanced placement courses) ។

* បុគ្គលិកសាលាមិនបានឆ្លើយតប នៅពេលសិស្សអាមេរិកដើមកំណើតអាស៊ីបានប្តឹងតវ៉ាទាក់ទងទៅ នឹងការយាយីខាងផ្ទៃ កពាក្យ សំដី និងខាងផ្ទៃ ករាងកាយ ដែលតែងតែកើតមានជាប្រចាំ ដែលបង្ក រឡើងដោយសិស្សផ្សេងទៀត។

ឧទាហរណ៍ទាំងនេះអាចចាត់ថាជាការរំលោភលើច្បាប់សហព័ន្ធ ដែលហាមឃាត់មិនឱ្យប្រកាន់រើសអើង សញ្ជាតិដើម របសជនណាម្ន ាក់ឡើយ នៅថ្ន ាក់បឋមសិក្សា វិទ្យ ាល័យ ( បឋមភូមិ និងទុតិយភូមិ) និងមហាវិទ្យ ាល័យ និងសាកលវិទ្យ ាល័យសាធារណៈឡើយ។ ផ្ន៉ែ កឱ កាសក្ន ុ ងការអប់រំ អនុវត្តច្បាប់ ឱ កាសក្ន ុ ងការអប់រំស្មើភាពគ្ន ា ឆ្ន ាំ ១៩៧៤ ដែលតម្រូវឱ្យទីភ្ន ាក់ងារអប់រំរដ្ឋ និងសាលារៀននៅតាមស្រុក

ចាត់វិធានការសមស្រប ដើម្បីដោះស្រាយឧបសគ្គភាសា ដែលរារាំងមិនឱ្យសិស្សរៀនភាសាអង់គ្លេស (ELL) ចូលរួមនៅក្នុងកម្មវិធីអប់រំស្មើគ្នា។ ផ្នែកនេះ ក៏អនុវត្តច្បាប់សហព័ន្ធ ដែលការពារសិស្សពីការរំលោភបំពាន ឬត្រូវបានចាត់ទុកថាខុសគ្នា ឬផ្សេងៗពីគ្នា ផ្អែកលើសញ្ជាតិដើមរបស់ពួកគេ។

សំរាប់ព័ត៌មានបន្ថែម រួមទាំងសេចក្តីណែនាំស្តីពីរបៀបដាក់ពាក្យបណ្តឹង សូមមើលវិបសាយរបស់ផ្នែកនេះ តាមអាសយដ្ឋាន www.justice.gov/crt/edo/ ។ អ្នកក៏អាចទំនាក់ទំនងមកកាន់ផ្នែកនេះដោយផ្ទាល់បានដែរ តាមរយៈទូរស័ព្ទលេខ (202) 514-4092 ឬ (877) 292-3804 ឬតាមរយៈអាសយដ្ឋានអ៊ីមែល education@usdoj.gov ។ អ្នកក៏អាចសរសេរសំបុត្រទៅអាសយដ្ឋាន:

U.S. Department of Justice
Civil Rights Division
Educational Opportunities Section, PHB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## ការងារ

** អ្នកត្រួតកម្មករនៅក្រុមហ៊ុនមួយ បានប្រើពាក្យមើលងាយប្រមាថពូជសាសន៍ ជាញឹកញាប់ចំពោះកម្មករ ដោយសារតែគ្រួសាររបស់ពួកគេមកពីប្រទេស អ៊ីរ៉ង់។ កាលពីអាទិត្យមុន ចៅហ្វាយនាយគេ បិទប្រកាសខ្លែងក្លាយ នៅលើក្តារបិទប្រកាសប្រាប់កម្មករទាំងអស់គ្នាថា កុំឱ្យទុកចិត្តកម្មកររូបនោះ ពីព្រោះគាត់ ជាភេរវជន។*

** ស្ត្រីម្នាក់ដែលធ្វើចំណាកស្រុកមកពីប្រទេសរុស្សី បានដាក់ពាក្យសុំធ្វើការធ្វើជាគណនេយ្យករ។ និយោជក*

*មិនទទួលយកគាត់ឱ្យធ្វើការទេ ពីព្រោះគាត់ និយាយភាសាអង់គ្លេសរបៀបបរទេស ទោះបីជាគាត់អាចអនុវត្តការងារបាន តាមល័ក្ខ ខ័ណ្ឌតម្រូវ ក៏ដោយ ។*

* *ក្រុមហ៊ ុនធ្វើម្ហូ បអាហារមួយតម្រូវឱ្យអ្ន កដាក់ពាក្យ សុំការងារធ្វើដែលទំនងដូចជាជនបរទេស ឬនិយាយមានសម្លេងដូចជនបរទេសឱ្យបង្ហាញនូវឯ កសារអនុញ្ញ ាតិឱ្យគេធ្វើការ មុននឹងអនុញ្ញ ាតឱ្យពួកគេបំពេញក្រដាសដាក់ពាក្យ សុំធ្វើការ ចំណែកឯ ជនស្បែកសដែលដាក់ពាក្យ សុំ ការងារធ្វើមិនត្រូវគេតម្រូវឱ្យបង្ហាញឯ កសារអ្វីទេមុននឹងគេបំពេញក្រដាសដាក់ពាក្យ សុំធ្វើការ ។ មិនតែប៉ុណ្ណេ ាះសោតក្រុមហ៊ ុននេះ ពិនិត្យ ពិច័យឯ កសាររបស់អ្ន កធ្វើការជនជាតិមានដើម កំណើតផ្សេងៗយ៉ាងល្អិ ិតល្អ ន់ ហើយគេទាត់ចោលច្រើនជាងឯ កសារស្រដៀងគ្ន ារបស់អ្ន កធ្វើការដែលមានដើមកំណើតជាជនជាតិ ស្បែកសដាក់ស្នើ ។*

ឧទាហរណ៍ទាំងនេះអាចចាត់ថាជាការរំលោភលើច្បាប់ដែលហាមឃាត់មិនអោយប្រកាន់រើសអើងចំពោះអ្ន កធ្វើការ ឬអ្ន កដាក់ពាក្យ សុំការងារធ្វើ ដោយសារតែសញ្ជាតិដើមរបស់ពួកគេឡើយ ។ នេះមានន័យថានិយោជកមិនអាចដាក់វិន័យ រំលោភបំពាន បណ្តេញចោលលែងឱ្យធ្វើការ បដិសេធមិនព្រមជួល ឬមិនព្រមឱ្យឡើងឋានៈ ដោយសារតែសញ្ជាតិដើមរបស់ពួកគេ ឡើយ ។

បើអ្ន កជឿជាក់ថានិយោជក អង្គការការងារ ឬទីភ្ន ាក់ងារជួយរកការឱ្យធ្វើណាប្រកាន់រើសអើងប្រឆាំងអ្ន ក ដោយសារតែសញ្ជាតិដើមរបស់អ្ន ក សូម ទំនាក់ទំនងមកកាន់ :

Equal Employment Opportunity Commission
(800) 669-4000
*(និយោជកដែលមានបុគ្គលិកលើសពី ១៥ នាក់)*

Office of Special Counsel
(800) 255-7688

U.S. Department of Justice
Civil Rights Division
Office of Special Counsel for Immigration-Related
Unfair Employment Practices, NYA
950 Pennsylvania Avenue, NW
Washington, D.C. 20530

osccrt@usdoj.gov

*(និយោជកដែលមានបុគ្គលិកលើសពី ៤ នាក់ ដល់ ១៤ នាក់)*

Employment Litigation Section
(202) 514-3831

U.S. Department of Justice
Civil Rights Division
Employment Litigation Section, PHB
950 Pennsylvania Avenue, NW
Washington, D.C. 20530

*(និយោជករដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋាន ដែលមានគំរូ*
*ឬការអនុវត្តន៏ការរើសអើងខុសច្បាប់)*

បន្ថែមលើនេះទៀត

និយោជកអាចរំលោភលើច្បាប់សហព័ន្ធដោយតម្រូវឱ្យមានឯ កសារអនុញ្ញ ាតឱ្យ
មានសិទ្ធិធ្វើការជាក់លាក់ ដូចជាប័ណ្ណ ហ្គ្រីនកាត (green card)
ឬមិនព្រមទទួលយកឯ កសារប្រភេទនេះ
ដោយសារតែសញ្ជាតិដើមរបស់អ្ន កដាក់ពាក្យ សុំការងារ
មួយចំនួនធ្វើតែប៉ុណ្ណោ ះ។ សំរាប់ព័ត៌ មានបន្ថែមទៀត
ឬដើម្បីដាក់ពាក្យ បណ្តឹងតវ៉ា សូមទំនាក់ទំនងទាក់ទងនឹងការិយាល័យ
ផ្តល់ប្រឹក្សាពិសេសនៅ នការិយាល័យនេះតាមអាសយដ្ឋាន ខាងលើ
ឬលេខទូរស័ព្ទឥតគិតថ្លៃ ឬអាសយដ្ឋានអ៊ីមែល។

## ការផ្តល់ទីជម្រក

* *គ្រួសារមួយមានសញ្ជាតិដើមជាជនជាតិហាវ៉ៃ ដើររកជួលអឹផាតម៉ឹន។*
*ភ្ន ាក់ងារជួលផ្ទះបានប្រាប់ពួកគេថា គេគ្មានផ្ទះបន្ទប់នៅទំនេរជួលឱ្យទេ*

*ទោះបីជាមាន អីផាតម៉ឺននៅទំនេរក៏ដោយ ហើយគេបានទាំងនាំបង្ហាញឱ្យ អ្ន កដាក់ពាក្យ សុំជួលជាជនជាតិស្បែកសមើលទៀតផង ។*

** អ្ន កលក់ដូរម្ន ាក់បង្ហាញឱ្យគ្រួសារមកពីប្រទេសអាមេរិកឡាទីនមើលតែផ្ទះណា ដែលមានទីតាំងនៅក្ន ុ ងសង្ក ាត់ដែលជនជាតិអាមេរិកឡាទីននៅពីមុន តែប៉ុណ្ណេ ាះ ហើយមិនព្រមបង្ហាញឱ្យគ្រួសារនេះមើលផ្ទះដែលឋិតនៅក្ន ុ ងសង្ក ាត់ដែលជនជាតិស្បែកសរស់នៅពីមុនទេ ។*

ឧទាហរណ៍ទាំងនេះអាចចាត់បានថារំលោភលើច្បាប់ស្តីពីការផ្តល់ទីជម្រកស្មើភាពគ្ន ារបស់សហព័ន្ធ ។ ច្បាប់នោះហាមឃាត់មិនឱ្យប្រកាន់រើសអើងដោយសារតែសញ្ជាតិដើម ពូជសាសន៍ ពណ៌ សម្បុ រ ភេទ សាសនា ពិការភាព ឬឋានៈគ្រួសារទេ ( មានកូនក្មេងអាយុក្រោម១៨ឆ្ន ាំ) រស់នៅក្ន ុ ងផ្ទះ ។ ការតវ៉ាអំពីការប្រកាន់រើសអើងរបស់បុគ្គលម្ន ាក់ៗអាចរាយការណ៍ជូនក្រសួង Housing and Urban Development (HUD) តាមរយៈទូរស័ព្ទលេខៈ (800) 669-9777 ។ បើអ្ន កជឿជាក់ថាមានគំរូ ឬការអនុវត្តន៍ការប្រកាន់រើសអើង សូមទំនាក់ទំនងមកកាន់ផ្ន ែក Housing and Civil Enforcement Section តាមរយៈទូរស័ព្ទលេខ (202) 514-4713 ឬ (800) 896-7743 ឬតាមរយៈអាសយដ្ឋានអ៊ីមែល fairhousing@usdoj.gov

។ អ្ន កក៏អាចសរសេរសំបុត្រទៅអាសយដ្ឋានៈ

U.S. Department of Justice
Civil Rights Division
Housing and Civil Enforcement Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## ការឱ្យខ្ចីប្រាក់

** ស្ត្រីជាតិអាមេរិកឡាទីនត្រូវគេយកការប្រាក់ និងថ្ល ៃ ជួលឈ្ន ួ លខ្ពស់ជាងអ្ន កមកខ្ចីដែលជាមនុស្សប្រុសស្បែកសដែលមាន*

*ប្រវត្តិហិរញ្ញ វត្ថុ ស្រដៀងគ្នា ហើយដាក់ពាក្យ សុំខ្ចីប្រាក់ប្រភេទដូចគ្នា ដែរ។*

ឧទាហរណ៍នេះអាចចាត់ជាការរំលោភលើច្បាប់សហព័ន្ធដែលហាមឃាត់មិនឱ្យប្រកាន់ រើសអើង ក្នុងការឱ្យខ្ចីប្រាក់ដោយសារតែសញ្ជាតិដើម ពូជសាសន៍ ពណ៌ សម្បុរ ភេទ សាសនា ពិការភាព និងស្ថានភាពគ្រួសារ ឬដោយសារតែប្រាក់ចំណូលខ្លះបានមក ពីជំនួយរបស់រដ្ឋរបស់ជនណាម្នាក់ ឬ ដោយសារជននោះបានអនុវត្តសិទ្ធិដែលត្រូវបានការពារដោយច្បាប់ការពារឥណទានរបស់អ្នកប្រើប្រាស់ឡើយ។ ប្រសិនបើ ប្រាក់កម្ចី គឺសម្រាប់ការបញ្ចាំផ្ទះ ឬកែលំអផ្ទះ ឬមូលហេតុផ្សេងៗដែលទាក់ទងនឹងការផ្តល់ទីជម្រក អ្នកអាចដាក់ពាក្យបណ្តឹងជាមួយនឹង ក្រសួង Housing and Urban Development តាមរយៈទូរស័ព្ទលេខ (800) 669-9777។ ប្រសិនបើប្រាក់កម្ចីសម្រាប់គោលបំណងផ្សេងទៀតក្រៅពីការផ្តល់ទីជម្រក (ដូចជាកម្ចីទិញរថយន្ត) អ្នកអាចដាក់ពាក្យបណ្តឹងជាមួយនឹងទីភ្នាក់ងារនិយ័តកម្ម អ្នកឱ្យខ្ចីប្រាក់ក៏បាន គណៈកម្មការពាណិជ្ជកម្មសហព័ន្ធក៏បាន ឬការិយាល័យអគ្គមេធាវីរបស់រដ្ឋក៏បាន។ អ្នកក៏អាចទំនាក់ទំនង Housing and Civil Enforcement Section តាមរយៈ ទូរស័ព្ទលេខ (202) 514-4713 ឬ (800) 896-7743 ឬតាមរយៈអាសយដ្ឋានអ៊ីមែល fairhousing@usdoj.gov ដើម្បីទទួលបានព័ត៌មានបន្ថែមទៀតអំពីសិទ្ធិរបស់អ្នក ឬធ្វើការដាក់ពាក្យបណ្តឹង។ អ្នកក៏អាចសរសេរសំបុត្រទៅអាសយដ្ឋាន :

U.S. Department of Justice
Civil Rights Division
Housing and Civil Enforcement Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## សេវាសាធារណៈ

* *នៅក្នុងភោជនីយដ្ឋានមួយ ជនជាតិអាមេរិកកាំងមានដើមកំណើតជាជនជាតិអាស៊ីចាំជាងមួយម៉ោងទំរាំមានអ*

៚ កបំរើតុមកបំរើ ចំណែកង ភ្ញៀ វជន ជាតិស្បែកស
និងជនជាតិអាមេរិកឡាទីនត្រូវគេបំរើភ្លាម ។

*អ្ន កទេសចរណ៍ជាតិអាមេរិកកាំងមានដើមកំណើតជាជនជាតិ ៃ ហទីដែលទៅ
សណ្ឋាគារ ត្រូវគេប្រាប់ថាពួកគេត្រូវតែបង់ ៃ ថ្លសណ្ឋាគារជាប្រាក់ មិនមែនប្រើ
ប័ណ្ណ ឥណទាន (Credit Card) ទេ
ហើយត្រូវបង់ ៃ ថ្លបន្ទប់ ៃ ថ្លជាងភ្ញៀ វដ ៃ ទទៀត
ហើយគេមិនផ្តល់ឱ្យនូវរបស់ប្រើប្រាស់ផ្សេង១ ដូចអ្ន កដ ៃ ទទៀត ដូចជា
កន្សែងជូតមុខ និងសាប៊ ូ ជាដើមទេ ។

ឧទាហរណ៍ទាំងនេះអាចចាត់បានថារំលោភលើច្បាប់សហព័ន្ធ
ដែលហាមឃាត់មិនឱ្យប្រកាន់រើសអើងដោយសារតែសញ្ជាតិដើម ពូជសាសន៍
ពណ៌ សម្បុ រ ឬសាសនានៅទីកន្លែងស្ន ាក់នៅជាសាធារណៈឡើយ ។
ការប្រើសេវាសាធារណៈ រួមមាន សណ្ឋាគារ ភោជនីយដ្ឋាន
និងទីកន្លែងកំសានផ្សេង១ ។ បើ អ្ន កជឿជាក់ថា
ថាមានគេមិនអនុញ្ញ ាតឱ្យប្រើ ឬមិនឱ្យមានសិទ្ធិ
កំសាន្តសប្បាយស្មើភាពនឹងអ្ន កដ ៃ ទទៀតក្ន ុ ងសេវាសាធារណៈទាំងនេ
ះ ហើយក្ន ុ ងករណី មានគំរូ ឬការអនុវត្តន៍ប្រកាន់រើសអើង
សូមទំនាក់ទំនងផ្ន ែ កអនុវត្តន៍ ច្បាប់ផ្តល់ទីជម្រក និងពលរដ្ឋ
តាមរយៈទូរស័ព្ទលេខ (202) 514-4713 ឬ (800) 896-7743
ឬតាមរយៈអាសយដ្ឋានអ៊ីមែល fairhousing@usdoj.gov
ដើម្បីទទួលបានព័ត៌ មានបន្ថែមទៀតអំពិសិទ្ធិរបស់អ្ន ក
ឬធ្វើការដាក់ពាក្យ បណ្តឹង ។ អ្ន កក៏អាចសរសេរសំបុត្រទៅ អាសយដ្ឋានៈ

U.S. Department of Justice
Civil Rights Division
Housing and Civil Enforcement Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## ការប្រព្រឹត្តខុសក្រមសីលធម៌ របស់នគរបាល

** នគរបាលបញ្ឈប់រថយន្តដែលបើកបរដោយជនជាតិអាមេរិកឡាទីនជានិច្ចចំពោះបទល្មើសច្បាប់ចរាចរណ៍មួយចំនួន ប៉ុន្តែមិនសូវបញ្ឈប់រថយន្ត ដែលបើកបរដោយ ជនជាតិស្បែកសចំពោះបទល្មើសនឹងច្បាប់ចរាចរណ៍ដូចគ្នាទេ។*

** នគរបាលម្នាក់*
*ដែលសួរបុរសម្នាក់ដែលមានដើមកំណើតជាជនជាតិវៀតណាមនៅតាមផ្លូវ មានការខឹងសម្បារ នៅពេលដែលបុរសនោះមិនអាចឆ្លើយនឹងសំនួររបស់ខ្លួនបាន ពីព្រោះគាត់មិនចេះ និយាយភាសាអង់គ្លេស។*
*នគរបាលក៏ចាប់បុរសនោះពីបទល្មើសណ្តាប់ធ្នាប់សាធារណៈ។*

ឧទាហរណ៍ទាំងនេះអាចចាត់បានថាជាការរំលោភលើខនៃច្បាប់ស្តីអំពីការការពារស្មើភាពគ្នានៃរដ្ឋធម្មនុញ្ញនៃស.រ.អា។ ឧទាហរណ៍ទាំងនេះក៏អាចចាត់បានដែរថាជាការរំលោភលើច្បាប់បង្ក្រាបឧក្រិដ្ឋកម្មទាំងឡាយ និងច្បាប់ចែងអំពីសុវត្ថិភាពតាមផ្លូវថ្នល់ឆ្នាំ ១៩៦៨ ផងដែរ។ ច្បាប់នោះហាមឃាត់ មិនឱ្យមានការរើសអើងដោយសារសញ្ជាតិដើម ពូជសាសន៍ ពណ៌សម្បុរ សាសនា ឬភេទ ពីសំណាក់ក្រសួងនគរបាល ដែលបានទទួលមូលនិធិសហព័ន្ធ តាមរយៈក្រសួងយុត្តិធម៌នៃស.រ.អាឡើយ។ ឧទាហរណ៍ទាំងនេះក៏អាចចាត់ថាជាការរំលោភលើចំណងជើងទីVI នៃច្បាប់ឆ្នាំ ១៩៦៤ ផងដែរ ដែលចែង អំពីសិទ្ធិពលរដ្ឋ ដែលហាមឃាត់មិនឱ្យមានការប្រកាន់រើសអើងពីសំណាក់ទីភ្នាក់ងារអនុវត្តន៍ច្បាប់ ដែលបានទទួលជំនួយផ្នែកហិរញ្ញវត្ថុអ្វីមួយរបស់សហព័ន្ធ រាប់បញ្ចូលទាំងធនធានដែលរឹបអូសបានពីឧក្រិដ្ឋជន។ ការនេះរួមទាំងទីភ្នាក់ងារអនុវត្តច្បាប់ រដ្ឋ និងមូលដ្ឋានជាច្រើន។

អ្នកអាចដាក់ពាក្យប្តឹងតវ៉ានានាអំពីការប្រកាន់រើសអើងរបស់ជនណាម្នាក់ ជាមួយនឹងផ្នែកសម្របសម្រួលសហព័ន និងត្រួតពិនិត្យការអនុវត្តតាមអាសយដ្ឋាន:

U.S. Department of Justice
Civil Rights Division
Federal Coordination and Compliance Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

ឬទំនាក់ទំនងផ្នែ   កសម្របសម្រួលសហព័ន្ធ និងត្រួតពិនិត្យ   ការអនុវត្ត តាមរយៈទូរស័ព្ទលេខ (888) 848-5306 ឬ (202) 307-2678 (TDD) ។

អ្ន   កក៏អាចដាក់ពាក្យ   ប្តឹងតវ៉ានានាអំពីការរើសអើងរបស់ជនណាម្ន   ាក់ ជាមួយនឹង Office of Justice Programs at Office for Civil Rights, Office of Justice Programs, U.S. Department of Justice, Washington, D.C. 20531ឬទូរស័ព្ទមកកាន់ការិយាល័យកម្មវិធីយុត្តិធម៌ (Office of Justice Programs) តាមរយៈលេខ (202) 307-0690 ។

ផ្នែ   កខាងរឿងក្តីពិសេស ស៊ើបអង្កេ   ត និងពិនិត្យ   រឿងក្តីអំពីការតវ៉ាថាក្រសួងនគរបាលមានគំរូ ឬការអនុវត្តន៍ប្រកាន់រើសអើង ដោយសារតែ សញ្ជាតិដើម ។ ដើម្បីដាក់ពាក្យ   បណ្តឹងតវ៉ា សូមទំនាក់ទំនង ផ្នែ   កខាងរឿងក្តីពិសេស តាមរយៈទូរស័ព្ទលេខ (202) 514-6255 ឬ (877) 218-5228 ។ អ្ន   កក៏អាចសរសេរសំបុត្រទៅអាសយដ្ឋានៈ

U.S. Department of Justice
Civil Rights Division
Special Litigation Section, PHB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## សិទ្ធិពលរដ្ឋរបស់មនុស្សចូលព្យ   ាបាលក្ន   ុងមន្ទីរព្យ   ាបាលជម្ង ឺផ្លូ   វចិត្ត

** ពន្ធនាគារមិនបកប្រែភាសាេ   នសវនាការស្តីអំពីវិន័យរបស់អ្ន   កជាប់ឃុំឃាំងេ ដលមិនចេះនិយាយភាសាអង់គ្លេសទេ ។*

** មន្ទីរពេទ្យ   វិកលចរិតរបស់រដ្ឋគ្មានមធ្យេ   ាបាយផ្តល់ឱ្យនូវការព្យ   ាបាលសំរាប់*

*មនុស្សណាដែលមិនចេះនិយាយភាសាអង់គ្លេសទេ ។*

ឧទាហរណ៏ទាំងនេះអាចចាត់ថា ជាការរំលោភលើខៃ នច្បាប់ស្ដីអំពីការការពារស្មើភាពគ្ន ាខៃ នរដ្ឋធម្មនុញ្ញ ខៃ នស.រ.អា. ។ ផ្នែ កច្បាប់ដែលវោងក្ដីពិសេស អនុម័តសិទ្ធិដែល រដ្ឋធម្មនុញ្ញ ផ្ដល់ឱ្យមនុស្សដែលជាប់ឃុំឃាំងនៅក្ន ុងមន្ទីរព្យ ាបាលជម្ងឺ ផ្លូ វចិត្តរបស់រដ្ឋ ឬរបស់រដ្ឋាភិបាលមូលដ្ឋាន ដូចជា ពន្ធនាគារ មន្ទីរ ឃុំឃាំង មន្ទីរឃុំខ្លួ នមុនការកាត់ទោស មន្ទីរអប់រំកែយុវជនយុវនារី គិលានដ្ឋានប្រតិបត្តិការជាសាធារណៈ វិទ្យ ាស្ថានសម្រាប់អ្ន កមានជម្ងឺវិកលចរិក្ត ឬមន្ទីរព្យ ាបាលមនុស្សដែលមិនលូតលាស់ដូចធម្មតា ។

បើអ្ន កជាអ្ន ករស់នៅក្ន ុងមន្ទីរព្យ ាបាលបែបនេះ ហើយអ្ន កជឿជាក់ថា មានគំរូ ឬការអនុវត្តន៍ប្រកាន់រើសអើង ដោយសារតែសញ្ជាតិដើមរបស់អ្ន ក សូម ទំនាក់ទំនងផ្នែ កវោងក្ដីពិសេស តាមរយៈទូរស័ព្ទលេខ : (202) 514-6255 ឬ (877) 218-5228 ។ អ្ន កក៏អាចសរសេរសំបុត្រទៅអាសយដ្ឋាន :

U.S. Department of Justice
Civil Rights Division
Special Litigation Section, PHB
950 Pennsylvania Avenue, NW
Washington, D.C. 20530

## កម្មវិធីទទួលជំនួយពីសហព័ន្ធ

** ទីភ្ន ាក់ងារសេវាសង្គមកិច្ចមូលដ្ឋានមិនផ្ដល់ព័ត៌ មាន ឬការបណ្ដុ ះបណ្ដាលការងារជាភាសាកូរ៉េឡើយ ទោះបីអ្ន ករស់នៅក្ន ុងមូលដ្ឋានចំនួន មួយភាគបួន ចេះនិយាយតែភាសាកូរ៉េក៏ដោយ ។*

** មន្ទីរពេទ្យ នៅក្ន ុងតំបន់ដែលមានប្រជាជនឡាទីនច្រើនបុគ្គលិកនេ ៅក្ន ុងមន្ទីរព្យ ាបាលអ្ន កជំងឺមិនសម្រាកនៅមន្ទីពេទ្យ ជាញឹកញាប់*

*តែងតែចំអក រិះគន់ពីរបៀបបញ្ចេញសម្លេង ហើយពេលខ្លះពន្យា ការផ្ដល់សេវាដល់អ្ន កជំងឺជនជាតិឡាទីន អ្ន កជម្ង ឺជាតិអាមេរិកឡាទីន ត្រូវបុគ្គលិកនៅ មន្ទីរពេទ្យ ប្រាប់គេឱ្យយកអ្ន បកប្រែភាសាមកជាមួយគេមុននឹងគ្រូពេទ ្យ អាចពិនិត្យ មើលជម្ង ឺរបស់គេបាន ។*

ឧទាហរណ៍ទាំងនេះអាចចាត់បានថាជាការរំលោភលើច្បាប់សហព័ន្ធ ដែលហាមឃាត់មិនឱ្យមានការប្រកាន់រើសអើងដោយសារតែសញ្ជាតិដើម ពូជសាសន៍ ឬពិ ណសម្ប ុ រពីកម្មវិធីដែលទទួលមូលនិធិរបស់សហព័ន្ធ ។ បើអ្ន កជឿជាក់ថា មានការប្រកាន់រើសអើងចំពោះរូបអ្ន កពីសំណាក់ ទីភ្ន ាក់ងាររដ្ឋាភិបាល រដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋាន ឬអង្គការណាដែលទទួលមូលនិធិពីរដ្ឋាភិបាលសហព័ន្ធ អ្ន កអាចដាក់ពាក្យ បណ្ដឹងតវ៉ាជាមួយ ផ្ន កសម្របសម្រួលសហព័ន្ធ និងត្រួតពិនិត្យ ការអនុវត្ត របស់ការិយាល័យនេះ តាមរយៈទូរស័ព្ទលេខ (888) 848-5306 ឬ (202) 307-2678 (TDD) ។ អ្ន កក៏អាចសរសេរសំបុត្រទៅ អាសយដ្ឋានៈ

U.S. Department of Justice
Civil Rights Division
Federal Coordination and Compliance Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

ផ្ន កសម្រសម្រួល និងត្រួតពិនិត្យ សារជាថ្មី នឹងបញ្ជូ នពាក្យ បណ្ដឹងបន្តទៅឱ្យទីភ្ន ាក់ងារសហព័ន្ធផ្ដល់មូលនិធិ (federal funding agency) ដែលទទួលខុសត្រូវជាចម្បងខាងការអនុវត្តន៏ការហាមមិនឱ្យមានការ ប្រកាន់រើសអើង ដែលទីភ្ន ាក់ងារទទួលជំនួយរបស់ខ្លួ នត្រូវតែអនុវត្តតាម ។

## ការបោះឆ្ន ោត

** មន្ត្រីទទួលបន្ទុ កខាងការបោះឆ្ន ោតម្ន ាក់តម្រូ វឱ្យអ្ន កបោះឆ ោត ដែលជាជនជាតិស្បែកខ្មៅដែលនិយាយភាសា របៀបបរទេស ហើយដែលមានឈ្មោះចម្លែក ឱ្យបង្ហាញភស្តុ តាងពលរដ្ឋអាមេរិកាំង*

*ក៏ប៉ុន្តែមិនបានតម្រូវឱ្យអ្ន កបោះឆ្នោ តមានស្បែកពិ ណេស បង្ហាញភស្តុ តាងពលរដ្ឋអាមេរិកាំងទេ។*

** ទោះបីមានសំណើពីអ្ន កមានសិទ្ធិបោះឆ្នោ តនៅក្នុ ងសហគមន៍និយាយភាសាអេស្ប៉ាញច្រើនក៏ដោយ ក្រុមមន្រ្តីខាងការបោះឆ្នោ តមិនព្រមផ្តល់មន្ត្រីបោះឆ្នោ ត ដែលបានបណ្តុ ះបណ្តាលភាសាអេស្ប៉ាញត្រឹមត្រូវ និងសម្ភា រៈបោះឆ្នោ តគ្រប់គ្រាន់ជាភាសាអេស្ប៉ាញឡើយ រួមមានក្រដាស បំពេញចុះឈ្មោះបោះឆ្នោ ត និង សន្លឹកឆ្នោ ត ឬក៏អនុញ្ញា តិឱ្យអ្ន កបោះឆ្នោ តដែលសមត្ថភាពនិយាយ ភាសាអង់គ្លេសនៅមានកម្រិត យកអ្ន កបកប្រែភាសាចូលទៅក្នុ ងបន្ទប់បោះឆ្នោ ត ជាមួយគេ។*

ផ្នែ កបោះឆ្នោ ត អាចចាត់វិធានការក្នុ ងការកែតម្រូវបញ្ហានានា ដូចដែលបានលើកឡើងនៅក្នុ ងឧទាហរណ៍ទាំងនេះ។ ច្បាប់សហព័ន្ធ ហាមឃាត់មិនឱ្យមានការ រើសអើងគ្រប់រូបភាពនៅក្នុ ងការបោះឆ្នោ ត រួមទាំងការបណ្តេញចេញ ការបំភិតបំភ័យ និងការរំលោភបំពានដល់អ្ន កបោះឆ្នោ ត ផ្អែ កលើពូជសាសន៍ ពណ៌ សម្បុ រ ឬដោយសារតែពួកគេនិយាយភាសាជនជាតិភាគតិចឡើយ។ បន្ថែមពីលើនេះទៀត ច្បាប់សហព័ន្ធ ក៏តម្រូវឱ្យមានយុត្តាធិការមួយចំនួន ដើម្បីផ្តល់នូវសម្ភា រៈ បោះឆ្នោ តជាភាសាជនជាតិភាគតិច និងជំនួយផ្នែ ក ភាសា ដើម្បីឱ្យអ្ន កដែលសមត្ថភាពភាសាអង់គ្លេសនៅមានកម្រិត អាចបោះឆ្នោ តបានត្រឹមត្រូវ និងមាន ប្រសិទ្ធភាព។ ច្បាប់ទាំងនេះក៏ផ្តល់ឱ្យអ្ន កបោះឆ្នោ ត ដែលត្រូវការជំនួយទាក់ទងនឹងសន្លឹកឆ្នោ ត ឬសម្ភា រៈបោះឆ្នោ តផ្សេងៗទៀត សិទ្ធិសុំជំនួយពីអ្ន កដទៃ ទ ដែលខ្លួ នបានជ្រើសរើស ( ក្រៅពីតំណាងណាម្ន ាក់ដែលមកពី និយោជក ឬសហជីពរបស់ខ្លួ ន)។ លើសពីនេះទៀត អ្ន កស៊ើបអង្កេ តរបស់សហព័ន្ធ ឬបុគ្គលិក ផ្នែ កបោះឆ្នោ ត អាចត្រួតពិនិត្យ ការអនុវត្តន៍នៅថ្ងៃ បោះឆ្នោ ត ដែល ជាការឆ្លើយតបទៅនឹងកង្វល់នានាអំពីការរើសអើង នៅក្នុ ងដំណើការបោះឆ្នោ ត និងកង្វះការ ប្រើប្រាស់ភាសាជនជាតិភាគតិច។ ផ្នែ កនេះ ក៏អាចចាត់វិធានការ ដើម្បីដោះស្រាយវិធីក្នុ ងការបោះឆ្នោ តផងដែរ ដូចជា ផែនការច្រើន

ឬផែនការស្រុក ដែលធ្វើឱ្យថយកម្លាំងបោះឆ្នោតរបស់ជនជាតិភាគតិច ។

បើអ្នកជឿជាក់ថា មានគេរើសអើងប្រឆាំងនឹងការបោះឆ្នោតរបស់អ្នក ឬបដិសេធមិនផ្តល់ជំនួយនៅក្នុងការបោះឆ្នោតរបស់អ្នក អ្នកអាចទំនាក់ទំនងផ្នែកបោះឆ្នោតរបស់ការិយាល័យនេះ តាមរយៈទូរស័ព្ទលេខ (800) 253-3931 ឬតាមរយៈអាសយដ្ឋានអ៊ីមែល voting.section@usdoj.gov ។ អ្នកក៏ អាចសរសេរសំបុត្រទៅអាសយដ្ឋានៈ

U.S. Department of Justice
Civil Rights Division
Voting Section, NWB
950 Pennsylvania Avenue, NW
Washington, D.C. 20530

ពេលអ្នកទូរស័ព្ទទៅការិយាល័យណាមួយ ដែលមានចុះផ្សាយនៅក្នុងកូនសៀវភៅផ្សព្វផ្សាយនេះ អ្នកនឹងឮចម្លើយជាភាសាអង់គ្លេស ។ បើអ្នកត្រូវការអ្នកបកប្រែភាសាសូមប្រាប់អូប៉េរ៉ាទ័រ (operator) ថាតើលោកអ្នកនិយាយភាសាអ្វី ។ អូប៉េរ៉ាទ័រនោះ នឹងឱ្យអ្នករង់ចាំនៅពេលដែលគេរកអ្នកបកប្រែជូនបាន ។ សូមកុំដាក់ទូរស័ព្ទចុះ ។ តាមរយៈសេវាអ្នកបកប្រែភាសា យើងអាចជួយសម្រួលដល់អ្នកទូរស័ព្ទចូលបានគ្រប់ភាសា ។

សំគាល់ : សំរាប់ជនពិការ ឯកសារនេះ នឹងមានជាអក្សរធំ កាសែតស្តាប់សម្លេង ឌីសថាសម៉ាស៊ីនកុំព្យូទ័រ និងអក្សរប្រៃយ៍ ។

អ្នកអាចចម្លងកូនសៀវភៅផ្សព្វផ្សាយនេះបានដោយសេរី ។

ចេញផ្សាយ ខែសីហា ឆ្នាំ ២០១០

# Federal Protections Against National Origin Discrimination

## Cambodian

www.justice.gov/crt




**United States Department of Justice**
Civil Rights Division

950 Pennsylvania Avenue, NW
Washington, D.C. 20530